សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

- *សូមថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី*
- *ជនរួមជាតិ ទាំងអស់ជាទីស្នេហា*

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាល សូមសម្តែងនូវបីតិសោមនស្សរីករាយយ៉ាងក្រៃលែង នៅពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសជាឯកច្ឆ័ន្ទឲ្យធ្វើជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ សម្រាប់អាណត្តិ ពីខែកុម្ភៈ ឆ្នាំ២០១៧ ដល់ខែកុម្ភៈ ឆ្នាំ២០១៨។

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសអភិវឌ្ឍន៍តិចតួចដំបូងគេ ដែលបានចរចាដោយជោគជ័យ និងក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។ បន្ទាប់ពីក្លាយជាសមាជិករួចមក រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ និងកំណែទម្រង់ស៊ីជម្រៅស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាដែលជាចលករជម្រុញឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនជាខ្លាំងក្លាគួរឲ្យកត់សម្គាល់ ដែលក្នុងនោះកំណើនផលិតផលក្នុងស្រុកសរុបរហូតដល់បច្ចុប្បន្នបានកើនឡើងជាមធ្យមក្នុងរង្វង់៧% កំណើនពាណិជ្ជកម្មកម្ពុជាក្នុងពាណិជ្ជកម្មអន្តរជាតិមានចំនួន ១៣ពាន់លានក្នុងឆ្នាំ២០១១ និងបានកើនឡើងរហូតដល់ជិត ៣០ពាន់លានក្នុងឆ្នាំ២០១៤ ព្រមទាំងបានកាត់បន្ថយភាពក្រីក្រពី ៥៣.២% ក្នុងឆ្នាំ២០០៤ មកនៅប្រមាណ ១១.៥% ក្នុងឆ្នាំ២០១៥។ ដោយគួបផ្សំលទ្ធផលវិជ្ជមាន នៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមនេះហើយ ដែលធ្វើឲ្យកម្ពុជាក្លាយជាប្រទេសគំរូដល់ប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀត ព្រមទាំងត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

ក្នុងតួនាទីនេះ ព្រះរាជាណាចក្រកម្ពុជា នឹងធ្វើការសម្របសម្រួលជាមួយប្រទេសអភិវឌ្ឍន៍តិចតួចដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំង ៣៦ និងប្រទេសសមាជិកសង្កេតការណ៍ចំនួន ៨ ផ្សេងទៀត ក្នុងចំណោមប្រទេសអភិវឌ្ឍន៍តិចតួចទាំងអស់សរុប ៤៨ ប្រទេស ដើម្បីជំរុញឲ្យការចរចាផ្នែកពាណិជ្ជកម្ម អាចសម្រេចបានជោគជ័យនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ១១ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១១ ដល់១៤ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុងប៊ុយអេណូស អៃរេស (Buenos Aires) នៃប្រទេសអាហ្សង់ទីន។

ប្រសិនជាកម្ពុជាបានសម្របសម្រួលឲ្យការចរចាក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១១ របស់អង្គការពាណិជ្ជកម្មពិភពលោក ទទួលបានជោគជ័យ ដែលនឹងធ្វើឲ្យសេដ្ឋកិច្ចពិភពលោកមានស្ថេរភាព ការទទួលយកតួនាទីស្មុលនេះនឹងជួយលើកតម្កើងថែមទៀតនូវកិត្តិស័ព្ទ និងកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ។ ក្នុងអំឡុងពេលបំពេញតួនាទីនេះ កម្ពុជាអាចសហការជាមួយប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀត ដើម្បីទាញយកផលប្រយោជន៍ពីការចរចាលើគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ សម្រាប់ជាឧត្តមប្រយោជន៍ដល់កម្ពុជា ក្នុងវិស័យនានាដូចជា ពាណិជ្ជកម្ម កសិកម្ម ទំនិញនាំចេញ សេវាកម្ម វិនិយោគ កម្មសិទ្ធិបញ្ញា និងបណ្តុះបណ្តាលធនធានមនុស្ស ដែលជាបច្ច័យដ៏ល្អសម្រាប់ការបង្កើតការងារថ្មីៗបន្ថែមទៀតដល់ប្រជាជនកម្ពុជា។

រាជរដ្ឋាភិបាល នឹងខិតខំឲ្យអស់ពីលទ្ធភាពដើម្បីបំពេញតួនាទីជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងដំណើរការចរចាសមាហរណកម្មសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌពិភពលោក។ ក្នុងតួនាទីនេះ កម្ពុជាអាចបង្ហាញជូនអន្តរជាតិនូវគោលនយោបាយអភិវឌ្ឍន៍ដ៏ត្រឹមត្រូវរបស់ព្រះរាជាណាចក្រកម្ពុជា។ ការរួមចំណែករបស់កម្ពុជា នឹងជួយតភ្ជាប់រវាងគោលនយោបាយសមាហរណកម្មពិភពលោក និងការអភិវឌ្ឍក្នុងតំបន់ ដើម្បីថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ និងអភិវឌ្ឍន៍។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា និងជនរួមជាតិទាំងអស់មេត្តាចូលរួមដោយសកម្មជាមួយរាជរដ្ឋាភិបាល ដើម្បីបំពេញតួនាទីជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ឲ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់ជាឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០១៧

**ហ៊ុន សែន**